**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងការពារជាតិ**

# សាររលិខិតរំលែកទុក្ខ

**ជម្រាបជូន**

**លោកជំទាវ សៀន ខាំគៀន ប៊ូ ថង ព្រមទាំងក្រុមគ្រួសារ**

តាងនាមថ្នាក់ដឹកនាំក្រសួងការពារជាតិ ក្នុងនាមខ្ញុំ និងភរិយា មានសេចក្ដីក្រៀមក្រំ និងក្ដុកក្ដួលក្នុងចិត្ត យ៉ាងក្រៃលែងចំពោះមរណភាពរបស់ ឯកឧត្តម នាយឧត្តមសេនីយ៍ **ប៊ូ ថង** សមាជិកព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា ដែលបានទទួលមរណភាព នៅវេលាម៉ោង ១:២០នាទីយប់ នាថ្ងៃទី១២ ខែ កញ្ញា ឆ្នាំ២០១៩ នៅក្នុងមន្ទីរពេទ្យកាល់ម៉ែត រាជធានីភ្នំពេញ ក្នុងជន្មាយុ ៨២ ឆ្នាំ ដោយរោគាពាធ។

មរណភាពរបស់ ឯកឧត្តម **ប៊ូ ថង** គឺជាការបាត់បង់ស្វាមី បិតា ជីតា ជាទីគោរពស្រឡាញ់ប្រកបដោយព្រហ្មវិហារធម៌ហើយក៏ជាការបាត់បង់ឥស្សរៈជនស្នេហាជាតិដ៏ឆ្នើមមួយរូប ដែលបានលះបង់ បូជាកម្លាំងកាយ កម្លាំងចិត្ត ប្រាជ្ញា ស្មារតី ហ៊ានបូជាជីវិត និងធ្វើពលិកម្មគ្រប់បែបយ៉ាង ជាពិសេសក្នុងបុព្វហេតុតស៊ូរំដោះប្រទេសជាតិ និងប្រជាជនពីរបបប្រល័យពូជសាសន៍ ហើយបានរួមចំណែកយ៉ាងសកម្ម ក្នុងវិស័យការពារជាតិ ក៏ដូចជាក្នុងការស្ដារ និងអភិវឌ្ឍប្រទេសជាតិឱ្យមានការរីកចម្រើនដល់បច្ចុប្បន្ន។ ទន្ទឹមនេះឯកឧត្តមបានខិតខំលើកកម្ពស់សិទ្ធិសេរីភាពគ្រប់បែបយ៉ាងរបស់បងប្អូនជនជាតិភាគតិច ហើយបានចូលរួមប្រែក្លាយតំបន់ភូមិភាគឦសាន ឱ្យក្លាយជាតំបន់មានការអភិវឌ្ឍរីកចម្រើនដ៏ឆាប់រហ័ស។

យើងខ្ញុំ សូមចងចាំនូវគុណវីរភាពដ៏ល្អប្រពៃរបស់ឯកឧត្តម នាយឧត្តមសេនីយ៍ **ប៊ូ ថង** ហើយរូបកាយរបស់ឯកឧត្តមបានបាត់បង់ក៏ពិតមែន តែកិត្តិយស គុណបំណាច់ កេរ្តិ៍ឈ្មោះ ស្នាដៃ និងឧត្តមគតិរបស់ឯកឧត្តម បានដក់ជាប់នៅក្នុងក្រអៅបេះដូងយើងខ្ញុំទាំងអស់គ្នាជានិច្ច។ យើងខ្ញុំសូមចូលរួមរំលែកទុក្ខដោយក្ដីសោកស្ដាយអាឡោះអាល័យបំផុត ជាមួយក្រុមគ្រួសារនៃសព និងសូមលំឱនកាយឧទ្ទិសបួងសួងដល់វត្ថុស័ក្តិសិទ្ធិក្នុងលោក សូមតាមជួយបីបាច់ថែរក្សាដល់ដួងវិញ្ញាណក្ខន្ធរបស់ ឯកឧត្តម នាយឧត្តមសេនីយ៍ **ប៊ូ ថង** ឆាប់បានបដិសន្ធិក្នុងសុគតិភព កុំបីឃ្លៀងឃ្លាតឡើយ។

សូម លោកជំទាវ ព្រមទាំងក្រុមគ្រួសារ ទទួលនូវការស្រឡាញ់រាប់អានដ៏ស្មោះស្ម័គ្រអំពីយើងខ្ញុំ។

ថ្ងៃព្រហស្បតិ៍ ១៤កើត ខែភទ្របទ ឆ្នាំកុរ ឯកស័ក ព.ស. ២៥៦៣
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១២ ខែ កញ្ញា ឆ្នាំ២០១៩
**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ**

សម្ដេចពិជ័យសេនា **ទៀ បាញ់**

វិថីហ្សកនីមីត្រូវ សង្កាត់មិត្តភាព ខណ្ឌ៧មករា រាជធានីភ្នំពេញ ទូរស័ព្ទ-ទូរសារ៖០២៣ ៨៨៣ ២៧៤: generalsec@mod.gov.kh